## អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
## អគ្គនាយកដ្ឋានស្រាវជ្រាវ
## នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- កម្ពុជាត្រូវបន្តពង្រឹងវិស័យធ្នឹងខ្នងសំខាន់ចំនួន៤ ស្តារនិងជំរុញកំណើនសេដ្ឋកិច្ច ឆ្នាំ២០២១-២០២៣
- កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់(RCEP) នឹងផ្តល់ភាពវិជ្ជមានជាច្រើនសម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជា
- ធនាគារជាតិនៃកម្ពុជា ជំរុញឱ្យ SME ចុះបញ្ជីក្នុងប្រព័ន្ធ ដើម្បីទទួលបានការគាំទ្រពីរដ្ឋ
- ផ្សារមូលបត្រកម្ពុជា គឺជាជម្រើសថ្មីនៃប្រភពទុនសម្រាប់ SME
- តើការនាំចេញសម្លៀកបំពាក់ និងស្បែកជើងកម្ពុជាឆ្នាំ២០២២ រំពឹងស្ទុះងើបឡើងខ្លាំងកម្រិតណា?
- ក្រសួងពាណិជ្ជកម្ម ផ្តល់លិខិតបញ្ជាក់ការនាំចេញ-នាំចូល ត្បូងពេជ្រមិនទាន់កែច្នៃ និងសល់ពីការកែច្នៃ
- វៀតណាមជាប្រទេសអាស៊ានដែលបានវិនិយោគច្រើនជាងគេបង្អស់នៅកម្ពុជា
- ទិន្នផលរោងចក្រនៅជប៉ុនកើនឡើងនៅក្នុងខែវិច្ឆិកា ដោយសារតែការផលិតឡានមានការកើនឡើង
- ក្រសួងពាណិជ្ជកម្មរបស់ថៃកំណត់គោលដៅនាំចេញនៅក្នុងឆ្នាំ២០២២ ចំនួន ៣,៤%
- សេដ្ឋកិច្ចសកលឆ្នាំ២០២២ ត្រូវបានព្យាករ នឹងមានទំហំលើស ១០០ទ្រីលានដុល្លារ
- ១/៣ នៃក្រុមហ៊ុនសាងសង់ ក្នុងវិស័យអចលទ្រព្យចិន នឹងអាចជួបបញ្ហាសាច់ប្រាក់ នៅពេលដែលការលក់ធ្លាក់ចុះ ៣០%
- គោលនយោបាយយុទ្ធសាស្ត្រថ្មីរបស់ចិន ដើម្បីរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចឆ្នាំ២០២២


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី១ ខែមករា ឆ្នាំ២០២២ លេខ ៖ ១០០

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## កម្ពុជាត្រូវបន្តពង្រឹងវិស័យឆ្អឹងខ្នងសំខាន់ចំនួន៤ ស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ឆ្នាំ២០២១-២០២៣



*ដោយ ខេមបូណ្ណមីស(ប្រាសាទបាយ័ន្ត ខេត្តសៀមរាប)*

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យប្រើប្រាស់នូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចក្នុងការរស់នៅជាមួយកូវីដ១៩តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ ដោយវិស័យធំ៤ ដែលត្រូវបន្តពង្រឹងបន្ថែម រួមមាន វិស័យកសិកម្ម-និងកសិឧស្សាហកម្ម, វិស័យទេសចរណ៍, វិស័យកាត់ដេរ និងវិស័យកម្មន្តសាលមិនមែនកាត់ដេរ។

១-វិស័យកសិកម្ម-និងកសិឧស្សាហកម្ម៖ ជាវិស័យដែលមានសក្តានុពលខ្ពស់ក្នុងការរក្សាស្ថិរភាពសេដ្ឋកិច្ចជាតិ និងធានាបាននូវសន្តិសុខស្បៀង។ ក៏ប៉ុន្តែវិស័យនេះក៏នៅជួបបញ្ហា ដែលត្រូវដោះស្រាយ និងពង្រឹងបន្ថែមទៀតដែរ ដូចជា ការធ្វើពិពិធកម្មដំណាំនៅមានកម្រិត និងកង្វះការវិនិយោគលើការកែច្នៃ និងមានបញ្ហាផ្សេងៗ។ រាជរដ្ឋាភិបាល នឹងផ្តោតជាសំខាន់លើការជំរុញកំណើនផលិតភាពកសិកម្ម, ការពង្រឹងភាពប្រកួតប្រជែងទាំងថ្លៃដើម និងគុណភាព, ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្នុងខ្សែចង្វាក់ផលិតកម្ម, ជំរុញការកែច្នៃ, ជំរុញឧស្សាហកម្មពូជដំណាំ និងការទាញយកប្រយោជន៍ឱ្យបានច្រើនបំផុតពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាដើម។

២-វិស័យទេសចរណ៍៖ សម្រាប់ឆ្នាំថ្មីខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជានឹងជំរុញទេសចរណ៍ជាតិ និងអន្តរជាតិទៅតាមផែនការដែលបានកំណត់ឱ្យមានភ្ញៀវទេចរក្នុងស្រុក ១១លាននាក់ ក្នុងឆ្នាំ២០២៣ និងបន្តបើកដំណើរការទទួលភ្ញៀវអន្តរជាតិដែលបានចាក់វ៉ាក់សាំងរួចឱ្យបានចំនួន ៧លាននាក់ត្រឹមឆ្នាំ២០២៥ ។

៣-វិស័យកាត់ដេរ ៖ រាជរដ្ឋាភិបាលកម្ពុជា បានជំរុញការអនុវត្ត នូវយុទ្ធសាស្ត្រនៃអភិវឌ្ឍន៏នៃវិស័យកាត់ដេរផលិតស្បែកជើង និងកាបូបកម្ពុជា ២០២១-២០២៥ ដើម្បីរក្សាភាពធន់ តម្លៃបន្ថែមខ្ពស់ និងជាពិសេស មានការប្រកួតប្រជែង និងជាមូលដ្ឋានគាំទ្រ ពិពិធកម្មសេដ្ឋកិច្ចផងដែរ។

៤-វិស័យកម្មន្តសាលមិនមែនកាត់ដេរ៖ វិស័យនេះមានសក្តានុពលធំធេង ជួយអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈការបន្តនិន្នាការផ្លាស់ប្តូរទីតាំងរោងចក្រ ការធ្វើពិពិធកម្មប្រភពផលិតកម្មរបស់ក្រុមហ៊ុនអន្តរជាតិមួយចំនួនមកកម្ពុជា ភាពអំណោយផលនៃការវិនិយោគនិងធុរកិច្ច ក៏ដូចជាកំណើនទីផ្សារ ច្បាប់ស្តីពីការវិនិយោគ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មនានាជាដើម។ ទាំងអស់នេះគឺជាអ្វីដែលកម្ពុជាត្រូវមានការដោះស្រាយ និងការកែលំអដើម្បីបន្តពង្រឹងសេដ្ឋកិចកម្ពុជាក្នុងឆ្នាំ២០២១-២០២៣។

ក្រោយមានការបើកដំណើរការប្រទេសឡើងវិញ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានរំពឹងថា សេដ្ឋកិច្ចកម្ពុជា នឹងមានកំណើនក្នុងរង្វង់ ៣% នៅឆ្នាំ២០២១ប្រសិនបើសេដ្ឋកិច្ចដំណើរការល្អ, ឆ្នាំ២០២២នឹងមានកំណើន ៤,២%។ ប៉ុន្តែនៅឆ្នាំក្រោយនេះ សេដ្ឋកិច្ចកម្ពុជាអាចនឹងមានកំណើនខ្ពស់ជាងការរំពឹងទុក៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ ខេមបូណ្ណមីស ចេញផ្សាយថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១។*

## ធនាគារជាតិនៃកម្ពុជា ជំរុញឱ្យ SME ចុះបញ្ជីក្នុងប្រព័ន្ធ ដើម្បីទទួលបានការគាំទ្រពីរដ្ឋ




*ដោយ ខេមបូណ្ណមីស*

វិស័យ SME រួមចំណែកយ៉ាងសំខាន់គាំទ្រកំណើនសេដ្ឋកិច្ច ហើយក៏ចូលរួមដល់ការពង្រឹងភាពធន់នៃសេដ្ឋកិច្ច តាមរយៈការបង្កើនការផ្គត់ផ្គង់ដើម្បីបំពេញតម្រូវការក្នុងស្រុក កាត់បន្ថយការពឹងផ្អែកលើការនាំចូលទំនិញមួយចំនួនពីបរទេស និងការបង្កើតការងារក្នុងស្រុក។

បើយោងតាមធនាគារអភិវឌ្ឍន៍អាស៊ី(ADB) សហគ្រាសធុនតូចនិងមធ្យម នៅកម្ពុជា ត្រូវបានប៉ាន់ស្មានថា មានប្រមាណ៩៩%នៃសហគ្រាសសរុប ដែលបានរួមចំណែកជិត៦០% នៃផលិតផលក្នុងស្រុក និងបង្កើតការងារជាង៧០% នៃកម្លាំងពលកម្ម។ ក៏ប៉ុន្តែវិស័យ SME នៅកម្ពុជា បច្ចុប្បន្នមានបញ្ហាប្រឈមជាច្រើន ដែលអាចជាឧបសគ្គក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

អគ្គនាយកបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជាបានលើកឡើងថា បញ្ហាប្រឈមក្នុងវិស័យ SME មានដូចជា ការខ្វះខាតជំនាញគ្រប់គ្រង និងពលកម្មជំនាញ ការខ្វះខាតប្រភពទុន និងលទ្ធភាពទទួលបានហិរញ្ញវត្ថុផ្លូវការ ខ្វះខាតផ្នែកព័ត៌មានទីផ្សារទាំងក្នុងស្រុកនិងទីផ្សារនាំចេញ ការប្រកួតប្រជែងពីសហគ្រាសធំៗ និង ពីការនាំចូលទំនិញពីបរទេស ជាដើម។ លើសពីនេះ ការរាលដាលនៃជំងឺកូវីដ-១៩ ក៏បានបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យSME។ បច្ចុប្បន្នសហគ្រាសទាំងអស់នោះ ស្ថិតក្នុងវិស័យក្រៅប្រព័ន្ធ ធ្វើឱ្យរាជរដ្ឋាភិបាលពិបាកគ្រប់គ្រងទិន្នន័យ ដើម្បីដាក់ចេញនូវគោលនយោបាយទ្រទ្រង់ និងជួយគាំទ្រឱ្យបានពេញលេញ។ ម៉្យាងទៀត វិបត្តិជំងឺកូវីដ-១៩ បានផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងរបៀបទំនាក់ទំនង ដោយការប្រើប្រាស់បច្ចេកវិទ្យាក្នុងផលិតកម្ម និងការជួញដូរកាន់តែមានភាពពេញនិយម ដែលទាមទារវិស័យSMEត្រូវពង្រឹងសមត្ថភាពបច្ចេកវិទ្យារបស់ខ្លួនឆ្លើយតបនឹងស្ថានភាពថ្មីនេះ។

មន្ត្រីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា បានជំរុញឱ្យសហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជាទាំងអស់ ចុះបញ្ជីក្នុងប្រព័ន្ធ ដើម្បីបង្កភាពងាយស្រួលដល់រាជរដ្ឋាភិបាលកម្ពុជា គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យនេះឱ្យកាន់តែរីកចម្រើន។ នៅពេលដែល សហគ្រាសធុនតូច និងមធ្យម បានចុះបញ្ជីក្នុងប្រព័ន្ធត្រឹមត្រូវ នោះពួកគេនឹងអាចទទួលបានអត្ថប្រយោជន៍ផ្សេងៗ ដែលដាក់ចេញដោយរាជរដ្ឋាភិបាល និងមានភាពងាយស្រួលក្នុងការទទួលបានកម្ចីហិរញ្ញប្បទានផងដែរ។ ការប្រើប្រាស់បច្ចេកវិទ្យាកាន់តែទូលំទូលាយ SME អាចនឹងទទួលបានព័ត៌មានឆាប់រហ័សពីតម្រូវការទីផ្សារ និងលើកកម្ពស់លទ្ធភាពទទួលបានហិរញ្ញវត្ថុផ្លូវការ តាមរយៈការ

កាត់បន្ថយបញ្ហាកង្វះព័ត៌មានជាក់លាក់ ដែលកន្លងមកបានធ្វើឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនមានភាពរារែកក្នុងការផ្តល់កម្ចីដល់ SME។ ក៏ប៉ុន្តែ ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាមិនមែនជាកិច្ចការងាយស្រួលនោះទេ ដោយទាមទារនូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលឱ្យបានទូលំទូលាយ គួបផ្សំនឹងការលើកកម្ពស់ចំណេះដឹងផ្នែកឌីជីថលរបស់ម្ចាស់សហគ្រាសធុនតូច និងមធ្យម និងជំនឿទុកចិត្តរបស់សាធារណជនទូទៅមកលើប្រព័ន្ធឌីជីថលផងដែរ ដែលទាំងអស់នេះទាមទារនូវការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់។ ដោយឡែក ក្រុមអ្នកជំនាញនៃវិស័យផ្សេងៗ និងស្ថាប័នពាក់ព័ន្ធ សុទ្ធតែបានឃើញថាវិស័យ SME នៅកម្ពុជានាពេលបច្ចុប្បន្ន ហាក់នៅមានកម្រិតនៅឡើយ និងមានបញ្ហាប្រឈមមួយចំនួន ដែលទាមទារឱ្យម្ចាស់អាជីវកម្មត្រូវពង្រឹងបន្ថែមនូវចំណេះដឹង និងសមត្ថភាព ក៏ដូចជា គុណភាពនៃការផលិត ដើម្បីអាចប្រកួតប្រជែងនិងចាប់យកឱកាសទីផ្សារ។ នៅប៉ុន្មានឆ្នាំខាងមុខ វិស័យ SME នឹងកាន់តែរីកចម្រើន និងចូលរួមកាន់តែខ្លាំង ក្នុងការគាំទ្រសេដ្ឋកិច្ចជាតិ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១។*

## កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ (RCEP) នឹងផ្តល់ភាពវិជ្ជមានជាច្រើនសម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជា



*ប្រភព៖ ភ្នំពេញ ប៉ុស្តិ៍, ២០២១ រូបភាព៖ សភាពាណិជ្ជកម្មកម្ពុជា*

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងពាណិជ្ជកម្មបានឱ្យដឹងថា កិច្ចព្រមព្រៀង RCEPគឺជាគំនិតផ្តួចផ្តើមរបស់អាស៊ាន ដែលបានចាប់ផ្តើមការចរចាតាំងពីឆ្នាំ ២០១២មក។ កិច្ចព្រមព្រៀងនេះ នឹងធ្វើឱ្យកម្ពុជាមានកំណើនប្រចាំឆ្នាំសម្រាប់ការនាំចេញចំនួន ៧,៣% ការវិនិយោគ ២៣,៤% និងផលិតផលក្នុងស្រុកសរុបប្រមាណ ២%លើផលិតផលក្នុងស្រុកសរុបដែលមាននាពេលបច្ចុប្បន្ន។

កិច្ចព្រមព្រៀង RCEP ដែលត្រូវចូលជាធរមាននៅថ្ងៃទី ១ ខែមករាឆ្នាំ២០២២ ខាងមុននេះ កម្ពុជានឹងទទួលបានអត្ថប្រយោជន៍ជាច្រើនរួមមានភាពអនុគ្រោះពន្ធពីកិច្ចព្រមព្រៀងនេះលើទំនិញជាច្រើន ដូចជា ទំនិញកសិកម្ម កសិកម្មកែច្នៃ ទំនិញឧស្សាហកម្ម ជាដើម។ លើសពីនេះកម្ពុជាក៏រំពឹងទទួលបានអត្ថប្រយោជន៍ បន្ថែមលើផ្នែកផ្សេងៗមួយចំនួនទៀតដូចជា ការផ្ទេរបច្ចេកវិទ្យា ចំណេះដឹង ចំណេះធ្វើ និងជំនាញថ្មីៗពីការ វិនិយោគផ្ទាល់ពីបរទេស ព្រមទាំងបង្កើតការងារដែលនឹងជួយជំរុញកំណើននៃការនាំចេញ និងកំណើនផលទុនសរុបក្នុងស្រុក និងជួយស្តារសេដ្ឋកិច្ច ប្រទេសឱ្យបានឆាប់រហ័ស។

លោក លឹម ហេង អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា បានបញ្ជាក់ថា កម្ពុជាមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកាន់តែច្រើនកាន់តែល្អ ហើយនៅឆ្នាំក្រោយនេះ ក្រៅពី RCEP ក៏មានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន មួយទៀតដែលត្រូវចូលជាធរមានផងដែរ។ កិច្ចព្រមព្រៀងទាំងអស់នេះ គឺជាឈ្នាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែរីកចម្រើន។

កិច្ចព្រមព្រៀងRCEP នឹងអនុញ្ញាតឱ្យកម្ពុជានាំចេញបានគ្រប់មុខទំនិញទៅប្រទេសសមាជិកអាស៊ានទាំង ១០ និងប្រទេសដៃគូពាណិជ្ជកម្មសេរីអាស៊ានចំនួន ៥

ទៀត។ RCEP ជាកិច្ចព្រមព្រៀងថ្នាក់តំបន់ ដូច្នេះកម្ពុជា ក៏មានបញ្ហាប្រឈមមួយចំនួន ជាពិសេសត្រូវប្រកួតប្រជែងជាមួយប្រទេសជិតខាងដែលនាំចេញផលិតផលកសិកម្ម ដូចជាប្រទេសវៀតណាម និងថៃ។

កសិកម្ម គឺជាទំនិញសំខាន់ និងចាំបាច់ ដែលយើងទទួលបានភាពអនុគ្រោះក្នុងកិច្ចព្រមព្រៀង RCEP ដូចនេះក្រៅពីការនាំចេញវត្ថុធាតុដើមកសិកម្មហើយ យើងក៏ត្រូវចេះកែច្នៃវត្ថុធាតុដើមដែលយើងមានផងដែរ។

ដើម្បីជំរុញឱ្យការនាំចេញរបស់កម្ពុជាមានកំណើន គឺត្រូវ ជំរុញផលិតកម្ម ដោយផ្ដេកលើកត្តាចំនួន ៤សំខាន់ រួមមាន៖១-ការទប់ស្កាត់ការរីកដុះដាលនៃទីផ្សារអចលនទ្រព្យ ២-ត្រូវបណ្ដុះបណ្ដាលកម្មករជំនាញឱ្យបានច្រើន ៣-ត្រូវលើកកម្ពស់វិស័យផលិត បច្ចេកទេស និងការប្រើប្រាស់គ្រឿងគីមី និង ៤-កាត់បន្ថយការប្រព្រឹត្តខុសនៅក្នុងវិស័យពន្ធដារ ដើម្បីបង្កើតឱ្យមានភាពស្មើគ្នានៅក្នុងការប្រកួតប្រជែង។

RCEP មានគោលបំណងបង្កើតបរិយាកាសពាណិជ្ជកម្ម និងវិនិយោគបើកចំហ ដើម្បីសម្រួលដល់ការពង្រីកពាណិជ្ជកម្ម និងការវិនិយោគក្នុងតំបន់ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសកលលោក។

RCEP នឹងក្លាយជាក្របខ័ណ្ឌស្នូលសម្រាប់ការធ្វើពាណិជ្ជកម្ម និងការវិនិយោគ ដើម្បីពង្រីកបន្ថែមទៀតនូវខ្សែសង្វាក់តម្លៃថ្នាក់តំបន់នាំមកនូវឱកាសទីផ្សារ និងការងារសម្រាប់អាជីវកម្ម និងប្រជាជនក្នុងតំបន់ ដែលនឹងគ្របដណ្ដប់លើប្រជាជនប្រមាណ ២,២ ប៊ីលាននាក់ ឬ ៣០% នៃចំនួនប្រជាជនពិភពលោក ផលិតផលក្នុងស្រុកសរុបប្រមាណ ២៦,២ ទ្រីលានដុល្លារ ឬ ៣០ %នៃផ.ស.ស របស់ពិភពលោក និងទំហំពាណិជ្ជកម្ម ២៨%នៃពាណិជ្ជកម្មពិភពលោក៕*ដោយ សេន ចន្ធូ*

*ប្រភព៖Post Khmers,ចេញផ្សាយថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១*

## តើការនាំចេញសម្លៀកបំពាក់ និងស្បែកជើងកម្ពុជាឆ្នាំ ២០២២ រំពឹងស្ទុះងើបឡើងខ្លាំងកម្រិតណា?



*រូបភាព៖ betterwork.org*

យោងតាមរបាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០២១ និងទិសដៅការងារពាណិជ្ជកម្មឆ្នាំ២០២២ របស់ក្រសួងពាណិជ្ជកម្ម បានឱ្យដឹងថា នៅរយៈពេល ១០ខែ ឆ្នាំ២០២១ ការនាំចេញ សម្ភារៈធ្វើដំណើរបានកើនឡើងជាង ៥០% និងការនាំចេញសម្លៀកបំពាក់បានកើនឡើងត្រឹម ៧% ប៉ុណ្ណោះបើប្រៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។ ក្នុងយៈពេលនេះដដែល កម្ពុជាសម្រេចបានទឹកប្រាក់នាំចេញជិត៩ពាន់លានដុល្លារ ពីការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងសម្ភារធ្វើដំណើរ។ ទោះជាយ៉ាងណាក្នុងរយៈពេល១០ខែនេះ ការនាំចេញសរុបរបស់កម្ពុជាបានថយចុះ ២% រីឯការនាំចូលមកវិញបានកើនដល់ទៅ ៥៨%ឯណោះ បើធៀបនឹង១០ខែឆ្នាំ២០២០។

ប្រធានសមាគមរោងចក្រាត់ដេរកម្ពុជា បានគូសបញ្ជាក់ថា ឧស្សាហកម្មកាត់ដេរ បានរីកចម្រើនខ្លាំងចាប់ពីពាក់កណ្ដាលទស្សវត្សរ៍៩០ ហើយបានក្លាយជាកត្តាលីករសំខាន់មួយសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា។ បើទោះបីជាកម្ពុជា បាននិងកំពុងជួបនូវវិបត្តិកូវីដ-១៩ ការនាំចេញសម្លៀកបំពាក់ វាយនភណ្ឌ នៅតែអាចដំណើរការជាធម្មតា។

សមាគមរោងចក្រកាត់ដេរ (GMAC) មានភាពជឿជាក់ ថា នៅឆ្នាំ២០២២ ខាងមុខ ការនាំចេញផ្នែកសម្ភារធ្វើដំណើរ នឹងបន្តកើនឡើងខ្ពស់ ខណៈការនាំចេញសម្លៀកបំពាក់វិញ នឹងកើនឡើងក្នុងកម្រិតមធ្យម។

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១។*

## ផ្សារមូលបត្រកម្ពុជា គឺជាជម្រើសថ្មីនៃប្រភពទុនសម្រាប់ SME




*ប្រភព៖ ភ្នំពេញ ប៉ុស្តិ៍ ២០២១ រូបភាព៖ ហ៊ិន រង្សី*

និយតករមូលបត្រកម្ពុជា និងសភាពាណិជ្ជកម្មកម្ពុជា បានជំរុញឱ្យសហគ្រាសធុនតូច និងមធ្យម(SME) នៅកម្ពុជា បោះផ្សាយលក់មូលបត្រ និងចុះបញ្ជីមូលបត្រនៅផ្សារមូលបត្រកម្ពុជា ដើម្បីទទួលបានជម្រើសហិរញ្ញប្បទានថ្មី និងមានរយៈពេលវែង ការលើកទឹកចិត្តពន្ធ និតន្តភាពអាជីវកម្មជាមួយនឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងដែលរឹងមាំជាងមុន។

លោក ស៊ូ សុជាតិ អគ្គនាយកនិយតករមូលបត្រកម្ពុជា (ន.ម.ក)បានលើកឡើងនៅក្នុងសិក្ខាសាលាស្តីពី«ជម្រើសហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា» ថា សហគ្រាសធុនតូច និងមធ្យម (SME) បានជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងជំនាញ ចំណេះដឹង បច្ចេកទេស ការបំពេញកាតព្វកិច្ចស្របច្បាប់ ការប្រកួតប្រជែងជាមួយសហគ្រាសបរទេស ពិសេសកង្វះខាតដើមទុន។លោកបានបន្តទៀតថា ដើម្បីរួមចំណែកជំរុញការអភិវឌ្ឍ(SME)នៅកម្ពុជា និយតករមូលបត្រកម្ពុជា បានធ្វើវិសោធនកម្មបទប្បញ្ញត្តិមួយចំនួន ដើម្បីអនុញ្ញាតឱ្យ SME បោះផ្សាយលក់មូលបត្រ និងចុះបញ្ជីមូលបត្រជាសាធារណៈនៅលើទីផ្សារកំណើននៃផ្សារមូលបត្រកម្ពុជា។

តាមរយៈការបោះផ្សាយលក់មូលបត្រជាសាធារណៈ នឹងផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ SME មានដូចជាការពង្រឹងកេរ្តិ៍ឈ្មោះ ការកាត់បន្ថយចំណាយលើហិរញ្ញប្បទានបើទោះបីតាមរយៈការខ្ចីពីធនាគារក៏ដោយហើយ ថែមទាំងពង្រឹងអភិបាលកិច្ចល្អ ការអនុវត្តដែលអនុលោមតាមច្បាប់ មានការលើកទឹកចិត្តពន្ធ និងជួយឱ្យក្រុមហ៊ុនដំណើរការប្រកបដោយតម្លាភាព និងយូរអង្វែង។

ទីផ្សារថ្មីសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម(SME) ឬមានឈ្មោះថា «ទីផ្សារកំណើន» ត្រូវបានផ្តួចផ្តើមឡើងដោយរដ្ឋាភិបាលកម្ពុជា ដើម្បីបន្ថែមនូវជម្រើសហិរញ្ញប្បទានមួយទៀតសម្រាប់ក្រុមហ៊ុនអាជីវកម្មទាំងនោះ ដែលមានផលរបរសរុបប្រចាំឆ្នាំលើសពី ១០ ប៊ីលានដុល្លារ និងបង្កើតការងារចំនួន ១,៣ លាន។

បច្ចុប្បន្នមានក្រុមហ៊ុន ២ ដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិនៅលើផ្សារកំណើននេះគឺក្រុមហ៊ុនសំណង់ DBD Engineering និងក្រុមហ៊ុន Telcotech។

ដើម្បីអាចចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជាបាន និយតករមូលបត្រកម្ពុជាតម្រូវឱ្យ(SME) ទាំងនោះត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចជា ត្រូវមានប្រវត្តិប្រតិបត្តិការអាជីវកម្មយ៉ាងតិច ១ ឆ្នាំ នៃកំណត់ត្រាអាជីវកម្ម មូលធនភាគហ៊ុនិកយ៉ាងតិច ២ ប៊ីលានរៀល (៥០ ម៉ឺនដុល្លារ)ប្រាក់ចំណេញសុទ្ធមិនមានការខាតបង់សម្រាប់ឆ្នាំសារពើពន្ធចុងក្រោយ ឬមានលំហូរសាច់ប្រាក់ពីប្រតិបត្តិការអាជីវកម្មវិជ្ជមាន ជាមួយនឹងចំណេញដុលយ៉ាងតិច ១០ %។ *ដោយ មុំ ចិន្តា*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០២១*

## ទីផ្សារទិញលក់លំនៅដ្ឋាន ក្រោយបើកប្រទេសជាង១ខែកន្លងមកនេះ



*សំណង់អាគារខ្ពស់ៗក្នុងរាជធានីភ្នំពេញ (រូបភាព៖ ហេង ភារម្យ)*

គិតមកទល់បច្ចុប្បន្នមានរយៈពេលជាង១ខែហើយ ដែលរាជរដ្ឋាភិបាលកម្ពុជាបានបើកប្រទេសលើគ្រប់វិស័យឡើងវិញ។ គេសង្កេតឃើញថា ការធ្វើពាណិជ្ជកម្ម និងការប្រកបអាជីវកម្មផ្សេងៗ ក៏បានវិលមករកភាពល្អប្រសើរឡើងវិញបណ្តើរៗផងដែរ។ ជាមួយគ្នានេះ វិស័យអចលនទ្រព្យ ក៏មានចរន្តទិញលក់ល្អប្រសើរជាងមុនដែរ។ ទីផ្សារផ្ទះល្វែង ដែលជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋវិញ ក៏ចាប់ផ្តើមមានចរន្តទិញលក់ល្អប្រសើរឡើងវិញផងដែរ បន្ទាប់ពីចរន្តចំណូលក្រោយបន្ទាប់ពីបើកប្រទេសឡើងវិញ ធ្វើឱ្យពួកគេមានលទ្ធភាពទិញផ្ទះល្វែង។

អគ្គនាយិកាក្រុមហ៊ុនអចលនទ្រព្យ PropNex កត់សម្គាល់ឃើញថា តម្រូវការផ្ទះល្វែងហាក់ពុំសូវទទួលបានការគាំទ្រខ្លាំងដូចពីមុននោះទេ។ នេះមកពីប្រជាពលរដ្ឋមួយចំនួនបានផ្លាស់ប្តូរការរស់នៅពីផ្ទះល្វែងទៅផ្ទះវីឡា និងការរស់នៅផ្ទះល្វែងនៅតាមផ្សារនានាជំនួសវិញ។ ការផ្លាស់ប្តូរផ្នត់គំនិតនេះ គឺបន្ទាប់ពីការប្រកបអាជីវកម្មនៅតាមផ្ទះល្វែងមិនមានដំណើរការល្អ និងមានការប្រកួតប្រជែងខ្លាំង ដែលពីការគិតរបស់ពួកគេកន្លងមកថា ទិញផ្ទះល្វែងបានទាំងរស់នៅ និងកន្លែងប្រកបអាជីវកម្ម។

ប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា បានបែងចែកតម្លៃផ្ទះល្វែងជាបីកម្រិត គឺកម្រិតមធ្យម ក្រោមមធ្យម និងលើមធ្យម។ ផ្ទះល្វែងដែលមានតម្លៃមធ្យម និងក្រោមមធ្យមហាក់មានទីផ្សារល្អជាងផ្ទះដែលមានតម្លៃលើមធ្យម ដែលភាគច្រើនគេទិញ ដើម្បីទុកចំណេញ។

វិស័យអចលនទ្រព្យនៅកម្ពុជា បានរងផលប៉ះពាល់ខ្លាំងដោយសារជំងឺកូវីដ-១៩ ព្រោះអ្នកលក់ និងអ្នកទិញមិនអាចជួបគ្នាបានព្រោះការទិញផ្ទះត្រូវមើលទីតាំងជាក់ស្តែង។ ប៉ុន្តែបច្ចុប្បន្នវិស័យអចលនទ្រព្យបានស្ទុះងើបឡើងវិញបណ្តើរៗហើយ ក្រោយរាជរដ្ឋាភិបាលសម្រេចបើកប្រទេសឡើងវិញ និងលើកលែងការធ្វើចត្តាឡីស័កចំពោះអ្នកដំណើរចូលមកកម្ពុជា ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ រួច ប៉ុន្តែភាគច្រើនជាអតិថិជននិងអ្នកវិនិយោគក្នុងស្រុកតែប៉ុណ្ណោះ។

អ្នកជំនាញរំពឹងថា វិស័យអចលនទ្រព្យកម្ពុជានឹងមានការរីកចម្រើនខ្លាំងនៅឆ្នាំ២០២២ ជាមួយកំណើនសន្សឹមៗ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១។*

## ការនាំចេញផ្លែមៀនប៉ៃលិន ទៅកាន់ទីផ្សារចិនវិវត្តដល់ណាហើយ?



*ដោយ ខេមបូណ្ឌមីស(រូបភាព៖សហគមន៍ផលិតផលមៀនប៉ៃលិន*

ផ្លែមៀនប៉ៃលិនរបស់កម្ពុជា ប្រមាណ៧០% នាំចេញទៅថៃ និងវៀតណាម ក្នុងតម្លៃប្រមាណជាង ១ ៥០០ រៀល ទៅ២ ០០០រៀលក្នុង១គីឡូក្រាម។ កន្លងមកតែងតែបានជួបបញ្ហាប្រឈម និងហានិភ័យគ្រប់ពេលវេលាប្រសិនបើមានការបិទ ឬរឹតបន្តឹងតាមព្រំដែនពីប្រទេសទាំងពីរ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើកិច្ចការបច្ចេកទេសនាំចេញទៅកាន់ទីផ្សារចិនឱ្យបានឆាប់ៗ ដើម្បីជួយដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ។ មកដល់ពេលនេះមន្ត្រីស្ថានទូតចិនប្រចាំនៅកម្ពុជា បានចុះពិនិត្យផ្ទាល់នៅចំការ រោងចក្រវេចខ្ចប់ និងសម្លាប់សមាសភាពចង្រៃ។ អគ្គរដ្ឋបាលគយចិន នឹងវាយតម្លៃនិងវិភាគហានិភ័យលើផ្លែមៀននេះពីចម្ងាយ តាមរយៈប្រព័ន្ធវីដេអូតាមការស្នើសុំរបស់កម្ពុជា។ ដើម្បីមានលទ្ធភាពចរចាបើកទីផ្សារឱ្យបានលឿន ចាំបាច់ត្រូវបំពេញលក្ខខណ្ឌតម្រូវភូតគាមអនាម័យ ស្តង់ដារគុណភាព និងសុវត្ថិភាពឱ្យបានពេញលេញ ដោយម្ចាស់ចំការ ត្រូវអនុវត្តបច្ចេកទេសដាំដុះតាមគោលការណ៍នៃការអនុវត្តកសិកម្មល្អ និងត្រូវមានការវិនិយោគសាងសង់រោងចក្រវេចខ្ចប់សម្លាប់សមាសភាពចង្រៃ តាមស្តង់ដារកំណត់ឱ្យបានគ្រប់គ្រាន់។ ការវាយតម្លៃ នឹងប្រព្រឹត្តិទៅនៅសប្តាហ៍ទី១នៅខែមករា ឆ្នាំ២០២២ ដោយជ្រើសរើសចំការតំណាងមួយចំនួន និងរោងចក្រចំនួន១នៅខេត្តប៉ៃលិន។

អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបងបានបញ្ជាក់ថា កន្លងមកមន្ទីរកសិកម្មខេត្តបាត់ដំបងបានចុះបណ្តុះបណ្តាលបច្ចេកទេសកសិកម្មល្អ(GAP) ម្ចាស់កសិដ្ឋានដាំដុះមៀនប៉ៃលិនបានចំនួន៣៣៥នាក់ នៅតាមស្រុកនានាក្នុងខេត្ត ក្នុងគោលបំណងន គឺដើម្បីឱ្យការដាំដុះ អាចឆ្លើយតបនឹងតម្រូវការទីផ្សារតំបន់ និងលើសកលលោក។ ក្នុងចំណោមអ្នកចូលរួមបណ្តុះបណ្តាលទាំងអស់មានតែម្ចាស់កសិដ្ឋាន ២៣នាក់ប៉ុណ្ណោះទទួលបានវិញ្ញាបនបត្របញ្ជាក់ពីការអនុវត្តន៍បច្ចេកទេសកសិកម្មល្អ ដែលជាវិញ្ញាបនបត្របញ្ជាក់ពីសមត្ថភាពក្នុងការអាចនាំចេញផ្លែមៀនប៉ៃលិនទៅកាន់ទីផ្សារអាស៊ាន។

មន្ត្រីជាន់ខ្ពស់នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តប៉ៃលិន និងបាត់ដំបង បានបង្ហាញពីក្តីរំពឹងខ្ពស់ចំពោះទីផ្សារចិនក្នុងការធ្វើឱ្យប្រសើរឡើងនូវទីផ្សារមៀនប៉ៃលិនរបស់កម្ពុជា ដែលកំពុងជួបបញ្ហារឿងតម្លៃ និងកង្វះទីផ្សារ។ លោកជឿជាក់ថា ទីផ្សារនិងតម្លៃផ្លែមៀនប៉ៃលិនរបស់កម្ពុជានឹងមានភាពល្អប្រសើរ ប្រសិនបើកម្ពុជាអាចនាំចេញត្រង់ទៅកាន់ប្រទេសចិន ដែលជាទីផ្សារដ៏ធំមួយប្រចាំតំបន់អាស៊ី៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូឌាមីស ចេញផ្សាយថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១។*

## ក្រសួងពាណិជ្ជកម្ម ផ្តល់លិខិតបញ្ជាក់ការនាំចេញ-នាំចូល ត្បូងពេជ្រមិនទាន់កែច្នៃ និងសល់ពីការកែច្នៃ




ក្រសួងពាណិជ្ជកម្ម បានផ្តល់លិខិតបញ្ជាក់ការនាំចេញ នាំចូល ត្បូងពេជ្រមិនទាន់កែច្នៃ និងសល់ពីការកែច្នៃ ក្នុងនោះ នាំចូល ១៥ច្បាប់ មានទឹកប្រាក់ ១៥លានដុល្លារ និងនាំចេញ ២១ច្បាប់ មានទឹកប្រាក់ ៩លានដុល្លារ។ ក្រសួងបានផ្តល់អាជ្ញាបណ្ណនាំចេញចំនួន៥១ច្បាប់ គិតជាទឹកប្រាក់ប្រមាណ ៦លានដុល្លារ, បាន

ពន្យារអាជ្ញាបណ្ណនាំចេញចំនួន ២២ច្បាប់ និងផ្តល់លិខិតជូនដំណឹងទំនិញឆ្លងកាត់ចំនួន ២៨ច្បាប់, បានផ្តល់អាជ្ញាបណ្ណនាំចូលចំនួន ៩ច្បាប់ គិតជាទឹកប្រាក់ប្រមាណ១លានដុល្លារ, បានពន្យារអាជ្ញាបណ្ណនាំចូលចំនួន ៥ច្បាប់។ ក្រៅពីនេះ ក្រសួងពាណិជ្ជកម្មបានចុះបញ្ជីសុំសិទ្ធិនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជូនរោងចក្រ និងក្រុមហ៊ុនសរុបចំនួន ១៩៣រួមមានៈ រោងចក្រកាត់ដេរសម្លៀកបំពាក់ចំនួន ៤១, រោងចក្រកាត់ដេរស្បែកជើង ចំនួន ១១, រោងចក្រផលិតកាបូបចំនួន ១៥, រោងចក្រផ្សេងៗ ចំនួន ៤៧ និងក្រុមហ៊ុនផ្សេងៗ ចំនួន ៧៩៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភពៈSWIFT NEWS ចេញផ្សាយថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០២១។*

# តារាងប្រចាំសប្តាហ៍

## តារាងទី១ៈពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិកលើមុខទំនិញនៅក្នុងខែតុលា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិកបង្ហាញថាៈ នៅក្នុងខែតុលា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិកមានទំហំទឹកប្រាក់សរុបចំនួន ១ ០៩១,៣លានដុល្លារ ដែលមានកំណើនប្រមាណជា ១១,៣% បើធៀបនឹងខែកញ្ញា ឆ្នាំ២០២១។

ជាក់ស្តែង ការនាំចូលទំនិញរបស់សហរដ្ឋអាមេរិកមកកម្ពុជា មានទំហំទឹកប្រាក់សរុប ៤៣,១លានដុល្លារនៅក្នុងខែតុលា ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ៧៣,៨% បើធៀបនឹងខែកញ្ញាឆ្នាំ២០២១ ។ ការនាំចូលទំនិញសំខាន់ៗទាំងនេះរួមមានៈ រថយន្តធ្វើដំណើរ ផលិតផលស្បែកសត្វ ប្លាស្ទា វ៉ាក់សាំង ឈាម និងផលិតផលផ្សេងៗទៀត។

ស្របពេលនោះដែរ ការនាំចេញទំនិញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់សរុប ១ ០៤៨,២លានដុល្លារ នៅក្នុងខែតុលា ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ៩,៧% បើធៀបនឹងខែកញ្ញា។ ការនាំចេញទំនិញនេះ ភាគច្រើនជាប្រភេទទំនិញរួមមានៈ ចង្កៀងនិងគ្រឿងបំភ្លឺអគ្គិសនី ការបូបយួរ ការបូបដាក់លុយ សំលៀកបំពាក់ និងផលិតផលផ្សេងៗទៀត៕

*ដោយ មិត្ត ចន្ទី*

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា |
|---|---|---|---|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **614.5** | **572.7** | **782.1** | **685.7** | **650.3** | **534.9** | **693.9** | **965.1** | **980.2** | **1,091.3** |
| កំណើន % | | -6.8% | 36.6% | -12.3% | -5.2% | -17.8% | 29.7% | 39.1% | 1.6% | 11.3% |
| នាំចូល | 33.9 | 33.3 | 39.1 | 29.4 | 38.1 | 28.8 | 33.2 | 43.0 | 24.8 | 43.1 |
| កំណើន % | | -1.8% | 17.4% | -24.8% | 29.6% | -24.4% | 15.3% | 29.5% | -42.3% | 73.8% |
| នាំចេញ | 580.6 | 539.4 | 743.0 | 656.3 | 612.2 | 506.1 | 660.7 | 922.1 | 955.4 | 1048.2 |
| កំណើន % | | -7.1% | 37.7% | -11.7% | -6.7% | -17.3% | 30.5% | 39.6% | 3.6% | 9.7% |

ប្រភពៈការិយាល័យជំរឿនសហរដ្ឋអាមេរិក និងទិន្នន័យណិជ្ជកម្មសហរដ្ឋអាមេរិក
(គិតជាលានដុល្លារ)

## តារាងទី២ៈចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសប្រចាំខែសីហា នៅឆ្នាំ២០២១

ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជាបង្ហាញថា នៅក្នុងខែសីហាឆ្នាំ២០២១នេះ រដ្ឋបាលថ្នាក់ជាតិ បានប្រមូលចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសសរុបចំនួន ១៥០, ២៣ប៊ីលានរៀល ដែលមានការធ្លាក់ចុះប្រមាណជា៥,៤%បើធៀបនឹងខែកក្កដា នៃឆ្នាំដដែល។

ជាក់ស្តែង ការប្រមូលចំណូលពន្ធ និងអាករលើការនាំចូលបានសរុបចំនួន ១៤៦,៦៩ប៊ីលានរៀល នៅក្នុងខែសីហាឆ្នាំ២០២១នេះ ដែលមានការធ្លាក់ចុះប្រមាណជា ១,៤% បើធៀបនឹងខែកក្កដា ឆ្នាំ២០២១។

ស្របពេលពេលនោះដែរ ការប្រមូលចំណូលពន្ធ និងអាករលើការនាំចេញបានសរុបចំនួន ៣,៥៤ប៊ីលានរៀលនៅក្នុងខែសីហាឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ២,៥% បើធៀបនឹងខែកក្កដា៕

*ដោយៈ មិត្ត ចន្ទី*

| បរិយាយ(គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា |
|---|---|---|---|---|---|---|---|---|
| **ចំណូលពន្ធលើ ពាណិជ្ជកម្មក្រៅប្រ ទេស** | **159.53** | **153.14** | **238.52** | **106.6** | **186.59** | **188.32** | **158.76** | **150.23** |
| កំណើន(%) | | -4.0% | 55.8% | -55.3% | 75.1% | 0.9% | -15.7% | -5.4% |
| ពន្ធ និងអាករលើការនាំចូល | 156.89 | 150.79 | 233.60 | 103.46 | 182.84 | 185.37 | 155.13 | 146.69 |
| កំណើន(%) | | -3.9% | 54.9% | -55.7% | 76.7% | 1.4% | -16.3% | -5.4% |
| ពន្ធ និងអាករលើការនាំចេញ | 2.64 | 2.35 | 4.92 | 3.12 | 3.75 | 2.95 | 3.63 | 3.54 |
| កំណើន(%) | | -11.0% | 109.4% | -36.6% | 20.2% | -21.3% | 23.1% | -2.5% |

*ប្រភព៖ តារាងប្រតិបត្តការហិរញ្ញវត្ថុសម្រាប់ខែសីហាឆ្នាំ២០២១នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ទិន្នផលរោងចក្រនៅជប៉ុនកើនឡើងនៅក្នុងខែវិច្ឆិកា ដោយសារតែការផលិតឡានមានការកើនឡើង



*កម្មករដើរនៅក្បែររោងចក្រក្នុងតំបន់ឧស្សាហកម្ម Keihin នៅ Kawasaki ប្រទេសជប៉ុន ថ្ងៃសុក្រ ទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧*
*រូបថតដោយ៖ REUTERS/Issei Kato*

ទិន្នផលរោងចក្ររបស់ជប៉ុននៅក្នុងខែវិច្ឆិកាកើនឡើង ជាពិសេសសេសវិស័យផលិតផលអូតូនៅក្នុងត្រីមាសទី៤ ឆ្នាំ២០២១ ដោយសារសេដ្ឋកិច្ច និងការផ្គត់ផ្គង់នៅក្នុងពិភពលោកងើបឡើងវិញ។

ផ្ទុយពីការកើនឡើងនេះ វិស័យកម្មន្តសាលនៅជប៉ុនមានកំណើនយឺត ដោយសារតែមានផលរំខានពីកូវីដ១៩ និងកង្វះការផ្គត់ផ្គង់បន្ទះឈីប។

ផលិតផលរោងចក្រនៅជប៉ុនកើនឡើង ៧,២ភាគរយ នៅក្នុងខែវិច្ឆិកា កាលពីខែមុន និងបានកើនឡើងខ្លាំងតាំងពីឆ្នាំ២០១៣ ដោយសារតែផលិតផលប្លាស្ទិក និងគ្រឿងក្រយានយន្តមានការកើនឡើង។

យោងតាមទិន្នន័យបានបង្ហាញថា ការផលិតឡាន និងម៉ូតូបានកើនឡើង ៤៣,១ភាគរយ នៅក្នុងខែវិច្ឆិកា បើធៀបទៅនឹងខែតុលា ខណៈដែលផលិតផលប្លាស្ទិកកើនឡើង ៩,៥ភាគរយ។

ទោះយ៉ាងណា ក្រុមហ៊ុនផលិតផលិតផលអូតូរបស់ Toyota Motor Corp បានលើកឡើងថា ខ្លួនបានពន្យាពេលផលិតផលិតផលអូតូឱ្យក្រុមហ៊ុននៅក្នុងស្រុកចំនួន៥ កាលពីខែមករា ដោយសារតែមានឧបសគ្គនៅក្នុងការផ្គត់ផ្គង់ និងដោយសារតែវិបត្តិសុខភាពកូវីដ១៩។

វិស័យកម្មន្តសាលនៅជប៉ុនត្រូវបានរំពឹងថា នឹងកើនឡើង ១,៦ភាគរយ នៅក្នុងខែធ្នូ និង ៥ភាគរយនៅក្នុងខែមករា។ នាំឱ្យរដ្ឋាភិបាលជប៉ុនបានបង្កើនការវាយតម្លៃលើទិន្នផលឧស្សាហកម្ម។

ទន្ទឹមនឹងនេះទិន្នន័យបានបង្ហាញថា អត្រាអ្នកអត់ការងារធ្វើនៅជប៉ុនបានកើនឡើងពី២,៧ភាគរយ ដល់ ២,៨ភាគរយនៅក្នុងខែវិច្ឆិកា បើធៀបទៅនឹងខែតុលា៕

*ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ REUTERS ចេញផ្សាយថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១*

## វៀតណាមជាប្រទេសអាស៊ានដែលបានវិនិយោគច្រើនជាងគេបង្អស់នៅកម្ពុជា




*រូបភាព៖ Vietnam News*

វៀតណាម គឺជាប្រទេសអាស៊ានមួយ ដែលបានវិនិយោគផ្ទាល់នៅកម្ពុជា ច្រើនជាងគេបំផុត ដែលបច្ចុប្បន្នមានគម្រោងវិនិយោគចំនួន១៨៨គម្រោង កំពុងមានសកម្មភាពនៅកម្ពុជាក្នុងដើមទុនចុះបញ្ជីសរុបជាង ២៨០០លានដុល្លារអាមេរិក។ វៀតណាម ក៏ជាដៃគូពាណិជ្ជកម្មធំរបស់កម្ពុជាដែរ ពិសេសជាទីផ្សារធំនាំចេញកសិផល។ បើមើលទៅលើការដោះដូរពាណិជ្ជកម្មវិញនៅ១១ខែកន្លងមកនេះ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងវៀតណាម កើនឡើង៨៤%ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន បើទោះបីជាមានជួបបញ្ហាប្រឈមនឹងវិបត្តិកូវីដ១៩ក្តី។ នៅក្នុងរយៈពេលនេះដែរ វៀតណាមក៏បានវិនិយោគគម្រោងថ្មីចំនួន ០៤ នៅកម្ពុជា ក្នុងដើមទុនចុះបញ្ជីជិត៩០លានដុល្លារអាមេរិក កើនឡើងជាង៤ដង បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ក្រុមហ៊ុនវៀតណាមដែលវិនិយោគធំជាងគេនៅកម្ពុជា គឺនៅតែជាក្រុមហ៊ុនទូរគមនាគមន៍ Viettel Cambodia ដែលជាក្រុមហ៊ុនមេរបស់ Metfone។ ក្រុមហ៊ុន Metfone មានតម្លៃសរុបប្រមាណ១ពាន់លានដុល្លារអាមេរិក ហើយបានបង់ពន្ធចូលរដ្ឋាភិបាលកម្ពុជាប្រមាណ ៨២០លានដុល្លារអាមេរិកផងដែរ គិតមកទល់ពេលនេះ។ ក្រៅពីនេះ ក៏មានក្រុមហ៊ុនវៀតណាម Thagrico វិនិយោគលើវិស័យកសិកម្ម ដាំដុះកៅស៊ូ ស្វាយចន្ទី ចេកអំបូងលឿងជាដើម។ ក្រុមហ៊ុនបានវិនិយោគនូវទឹកប្រាក់ប្រមាណ ៣៨៨លានដុល្លារ ដាំដូងប្រេង កៅស៊ូ និងដំណាំហូបផ្លែផ្សេងទៀត។ ក្រុមហ៊ុនមានមហិច្ឆតានាំចេញផ្លែចេកស្រស់ពីកម្ពុជាឱ្យបានដល់ ១ពាន់លានដុល្លារអាមេរិក ហើយក៏មានផែនការពង្រីកការវិនិយោគ ១០០លានដុល្លារបន្ថែមទៀត នៅឆ្នាំក្រោយនេះ លើវិស័យកសិកម្ម និងការចិញ្ចឹមសត្វនៅកម្ពុជា និងអាចបង្កើនការវិនិយោគបន្ថែម ៥០០លានដុល្លារទៀត ប្រសិនបើមានតម្រូវការចាំបាច់។

ក្រុមហ៊ុនវៀតណាមនៅកម្ពុជា ក៏បានស្នើឱ្យរដ្ឋាភិបាលកម្ពុជាមានការផ្លាស់ប្តូរមួយចំនួន ដើម្បីជួយឱ្យអាជីវកម្មរបស់ពួកគេកាន់តែមានភាពងាយស្រួលជាងមុន ពិសេសទាក់ទងនឹងបញ្ហាកង្វះថាមពលតែម្តង៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១។*

## ក្រសួងពាណិជ្ជកម្មរបស់ថៃកំណត់គោលដៅនាំចេញនៅក្នុងឆ្នាំ២០២២ ចំនួន ៣,៤%



*កិច្ចប្រជុំនៅក្រសួងពាណិជ្ជកម្មរបស់ថៃ*

*រូបថតដោយ៖ Bangkok Post*

ក្រសួងពាណិជ្ជកម្មរបស់ថៃបានកំណត់គោលដៅកំណើននៃការនាំចេញចំនួន ៣,៤ភាគរយ សម្រាប់ឆ្នាំ២០២២ កើនឡើង ១៦ភាគរយ ធៀបនឹងឆ្នាំមុន ទាបជាងការព្យាករណ៍របស់អង្គការឯកជន ដោយផ្អែកលើហេតុផលចំនួនប្រាំគឺ៖ ១.ការរីករាលដាលកូវីដ១៩មានរយៈពេលយូរ ២.អតិផរណាមានការកើនឡើងជាបន្តបន្ទាប់ ៣.ការចាត់វិធានការសុខាភិបាលសាធារណៈមានលក្ខណៈតឹងរឹង ៤.កង្វះកម្លាំងពលកម្ម និង ៥.កង្វះឧបករណ៍អេឡិចត្រូនិក។

អង្គការដែលមានមូលដ្ឋាននៅទីក្រុងប៉ារីសបាននិយាយថា កូវីដបំប្លែងថ្មីអូមីក្រុងវ៉ារ្យ៉ង់កាន់តែឈានទៅរកភាពធ្ងន់ធ្ងរ នាំឱ្យរដ្ឋាភិបាលចាត់វិធានការតឹងរឹងដែលជា

ហេតុនាំឱ្យប៉ះពាល់ដល់តម្រូវការទំនិញ និងសេវាកម្ម។ កត្តានេះបានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងអតិផរណាទាប។ ស្ថានភាពនេះស្រដៀងនឹងកម្រិតដំបូងបំផុតនៅក្នុងដំណាក់កាលនៃជំងឺរាតត្បាតកូវីដ១៩។

អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ (OECD) បានធ្វើបច្ចុប្បន្នភាពលើការព្យាករណ៍សេដ្ឋកិច្ចពិភពលោកនៅក្នុងឆ្នាំនេះចំនួន ៥,៦ភាគរយនៅក្នុងឆ្នាំ២០២១ ទាបជាងការព្យាករណ៍លើកមុនដែលមានកំណើនដល់ទៅ ៥,៧ភាគរយ។ ប៉ុន្តែការព្យាករណ៍សម្រាប់ឆ្នាំ២០២២ នៅតែមានកំណើនដដែលគឺ ៤,៥ភាគរយ។

ក្រសួងពាណិជ្ជកម្មរបស់ថៃបានរំពឹងថា កំណើនវិស័យពាណិជ្ជកម្មថៃនឹងមានអត្រា ៥,៧ភាគរយនៅក្នុងឆ្នាំ២០២២។ ប៉ុន្តែសភាពាណិជ្ជកម្មថៃ ដែលដំណាងឱ្យគណៈកម្មាធិការអចិន្ត្រៃយទទួលបន្ទុកលើវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម និងធនាគារបានកំណត់គោលដៅកំណើននៃការនាំចេញរបស់ថៃចន្លោះពី ៣ភាគរយ ទៅ ៥ភាគរយ ខ្ពស់ជាងការព្យាករណរបស់ក្រសួងពាណិជ្ជកម្មបន្តិច ដោយសារលុយបាតធ្លាក់ចុះ និងដោយសារតែមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលជាមួយវិស័យឯកជនកាន់តែមានភាពប្រសើរឡើង។ សភាពាណិជ្ជកម្មថៃបានស្នើរឱ្យរដ្ឋាភិបាលពន្លឿនកិច្ចខិតខំប្រឹងប្រែង ដើម្បីលុបបំបាត់ច្បាប់ និងបទបញ្ញត្តិហួសសម័យដែលរារាំងដល់សកម្មភាពអាជីវកម្ម និងសេវាកម្មសាធារណៈនៅឆ្នាំក្រោយ៕ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ Bangkok Post ចេញផ្សាយថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១*

## ពាណិជ្ជកម្មក្រៅប្រទេសរបស់ហ្វីលីពីនក្នុងខែតុលា ឆ្នាំ ២០២១

នៅក្នុងខែតុលា ឆ្នាំ២០២១ ពាណិជ្ជកម្មក្រៅប្រទេសសរុបរបស់ហ្វីលីពីនមានតម្លៃចំនួន ១៦,៨៤ប៊ីលានដុល្លារ ដែលមានកំណើនប្រចាំឆ្នាំ ១៥,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ ដែលមានកំណើនអវិជ្ជមាន១០%។ ក្នុងចំណោមពាណិជ្ជកម្មសរុបមាន៦១,៩% ជាទំនិញនាំចូល ក្រៅពីនេះជាទំនិញនាំចេញ។

នៅក្នុងខែតុលាឆ្នាំ២០២១ ការនាំចេញសរុបមានតម្លៃ ៦,៤១ប៊ីលានដុល្លារដែលមានកំណើនប្រចាំឆ្នាំ ២% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅមានកំណើនអវិជ្ជមាន ០,៩%។ ចំណែក ការនាំចូលវិញមានតម្លៃ ១០,៤២ប៊ីលានដុល្លារ កំណើនប្រចាំឆ្នាំ ២៥,១% ធៀបនឹងឆ្នាំ២០២០ មានកំណើនអវិជ្ជមាន ១៥,៩% មានតម្លៃត្រឹមតែ ៨,៣៣ប៊ីលានដុល្លារ។

ជារួមតុល្យភាពពាណិជ្ជកម្មរបស់ហ្វីលីពីនក្នុងខែតុលាមានឱនភាពចំនួន -៤,០២ប៊ីលានដុល្លារ ជាមួយការកើនឡើងប្រចាំឆ្នាំ ៩៦,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ មានកំណើនអវិជ្ជមាន ៤២,៧%៕

*ដោយ មុំ ចិន្តា*

### តារាងសង្ខេបពាណិជ្ជកម្មក្រៅប្រទេសសម្រាប់ខែកញ្ញា និងតុលាឆ្នាំ២០២១(គិតជាលានដុល្លារ)

| បរិយាយ | តុលា ២០២០ | | កញ្ញា២០២១ | | តុលា ២០២១ | |
|---|---|---|---|---|---|---|
| | តម្លៃ | % | តម្លៃ | % | តម្លៃ | % |
| នាំចូល | 8,335.45 | (15.9) | 10,683.91 | 24.9 | 10,427.83 | 25.1 |
| នាំចេញ | 6,287.05 | (0.9) | 6,688.73 | 6.4 | 6,411.24 | 2.0 |
| តុល្យភាពពាណីជ្ជកម្ម | - 2,048.40 | (42.7) | - 3,995.18 | 76.3 | - 4,016.59 | 96.1 |
| ពាណិជ្ជកម្មសរុប | 14,622.50 | (10.0) | 17,372.64 | 17.1 | 16,839.07 | 15.2 |

*ប្រភព៖ Philippine statistics authority*

## ពាណិជ្ជកម្មរវាងវៀតណាម និងអឺរ៉ុបឆ្នាំ២០២១ និងក្តីរំពឹងឆ្នាំ២០២២



*ដោយ ខេមបូណូមីស*

ទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មវៀតណាម-អឺរ៉ុប ក្រោមមូលដ្ឋានគ្រឹះដ៏រឹងមាំនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី សហភាពអឺរ៉ុប-វៀតណាម (EVFTA) នឹងផ្តល់នូវផលប្រយោជន៍ច្រើនដល់ភាគីទាំងសងខាងនៅក្រោយជំងឺកូវីដ១៩ត្រូវបានបញ្ចប់។ ការនាំចេញទំនិញរបស់វៀតណាមទៅកាន់ទីផ្សារសហភាពអឺរ៉ុបនៅឆ្នាំ ២០២២ ត្រូវបានគេរំពឹងថានឹងមានកំណើនច្រើនជាងឆ្នាំ ២០២១។ រយៈពេល ២ ឆ្នាំបន្ទាប់ពី ការផ្ទុះឡើងនៃជំងឺកូវីដ១៩ ទាំងវៀតណាម និងសហភាពអឺរ៉ុបបានសម្របខ្លួនកាន់តែប្រសើរឡើងចំពោះជំងឺរាតត្បាតសកលមួយនេះ ហើយក៏បានកំពុងពន្លឿនការចាក់វ៉ាក់សាំងដូសជាមូលដ្ឋាន និងការចាក់វ៉ាក់សាំងដូសជំរុញផងដែរ។

ស្ថិតិពីគយវៀតណាមបានបង្ហាញថា ទំហំពាណិជ្ជកម្មរវាងវៀតណាម និងសហភាពអឺរ៉ុបឈានដល់ជាង ៥១ ពាន់លានដុល្លារក្នុងរយៈពេល ១១ ខែនៃឆ្នាំ ២០២១ កើនឡើងជិត ១៤%ក្នុងរយៈពេលដូចគ្នាបើធៀបទៅនឹងឆ្នាំ ២០២០ បើទោះបីជានៅអំឡុងពេលនេះ មានការរំខានមេរោគកូវីដ១៩រាតត្បាតយ៉ាងណាក្តី។ ក្នុងនោះ ការនាំចេញរបស់វៀតណាមទៅអឺរ៉ុបកើនឡើងជាង ១២% និងការនាំចូលពីអឺរ៉ុបមកវិញកើនឡើងប្រមាណ ១៦%។ វៀតណាមទទួលបានអតិរេកពាណិជ្ជកម្ម កើនឡើងជិត ១០% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ជំងឺកូវីដ១៩ បានជះឥទ្ធិពលអវិជ្ជមានដល់រាល់សកម្មភាពពាណិជ្ជកម្ម និងវិនិយោគរបស់វៀតណាម ប៉ុន្តែការអនុវត្តពាណិជ្ជកម្មសេរីអឺរ៉ុប-វៀតណាម បានជួយដោះស្រាយវិបត្តិសេដ្ឋកិច្ច និងនាំមកនូវឱកាសទីផ្សារចម្រុះថែមទៀតសម្រាប់អាជីវកម្មវៀតណាម។ ដូចនេះហើយ សក្តានុពលសម្រាប់ការនាំចេញរបស់វៀតណាមទៅកាន់អឺរ៉ុបនៅតែមានទំហំធំក្នុងពេលខាងមុខ នៅពេលដែលសេដ្ឋកិច្ចអឺរ៉ុបងើបឡើងវិញ ដែលធ្វើឱ្យតម្រូវការនាំចូលនៃតំបន់មួយនេះកាន់តែកើនឡើង៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១។*

# សេដ្ឋកិច្ចសកល

## សេដ្ឋកិច្ចសកលឆ្នាំ២០២២ ត្រូវបានព្យាករ នឹងមានទំហំលើស ១០០ទ្រីលានដុល្លារ



*ប្រភព៖ Times of India ២០២១*

មជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងធុរកិច្ច បានព្យាករថា ទំហំសេដ្ឋកិច្ចសកល នឹងសម្រេចបានលើស ១០០ ទ្រីលាន នៅឆ្នាំ២០២២ លឿនជាងការព្យាករលើកមុន ចំនួន ០២ឆ្នាំ ដែលការព្យាករនេះ ដូចគ្នានឹងការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)។

ជាក់ស្តែង ផលិតផលក្នុងស្រុកសរុប សកល បានងើបឡើងវិញពីវិបត្តិជំងឺរាតត្បាត ក៏ប៉ុន្តែ ជាមួយនឹងការកើន

ឡើងនៃអតិផរណា វាអាចនឹងផ្តល់ភាពលំបាកដល់អ្នកធ្វើច្បាប់ ក្នុងការចៀសវាងកុំឱ្យសេដ្ឋកិច្ចធ្លាក់ចូលទៅក្នុងវិបត្តិវិញ។

ទន្ទឹមនេះ លោក Douglas McWilliams អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងធុរកិច្ច បានលើកឡើងថា ក្នុងទស្សវត្សរ៍ឆ្នាំ២០២០នេះ វិធីសាស្ត្រក្នុងការដោះស្រាយអតិផរណា គឺជាបញ្ហាចម្បងដែលសេដ្ឋកិច្ចសកលត្រូវពិចារណា។ ក្នុងលក្ខខណ្ឌដែលអតិផរណាមិនអាចគ្រប់គ្រងបាន នោះសេដ្ឋកិច្ចសកលនឹងអាចធ្លាក់ចូលទៅក្នុងវិបត្តិនៅឆ្នាំ២០២៣ ឬឆ្នាំ២០២៤។

បន្ថែមពីនេះដែរ នៅក្នុងតារាងសេដ្ឋកិច្ចសកលប្រចាំឆ្នាំរបស់មជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងធុរកិច្ច បានធ្វើការព្យាករទុកមួយចំនួន ដូចជា៖

- ✓ សេដ្ឋកិច្ចប្រទេសចិន នឹងមានទំហំធំជាងសេដ្ឋកិច្ចសហរដ្ឋអាមេរិកនៅឆ្នាំ២០៣០
- ✓ សេដ្ឋកិច្ចឥណ្ឌា នឹងស្ថិតនៅចំណាត់ទី៦ ជាថ្មីម្តងទៀត នៅឆ្នាំក្រោយនេះ ហើយនឹងក្លាយជាសេដ្ឋកិច្ចធំទី៣ លើសកលលោក នៅឆ្នាំ២០៣១
- ✓ សេដ្ឋកិច្ចចក្រភពអង់គ្លេស នឹងមានទំហំជាងសេដ្ឋកិច្ចបារាំង ១៦% ថ្វីបើចាកចេញពីសហគមន៍អឺរ៉ុប
- ✓ ការផ្លាស់ប្តូរអាកាសធាតុ នឹងកាត់បន្ថយការចំណាយអ្នកប្រើប្រាស់ ក្នុងទំហំជាមធ្យម ២ទ្រីលានដុល្លារ ក្នុង១ឆ្នាំ រហូតដល់ឆ្នាំ ២០៣៦៕

*ដោយ **ជា សិរីរតន៍***

*ប្រភព៖ Times of India ចេញផ្សាយ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១*

## ១/៣ នៃក្រុមហ៊ុនសាង់សង់ ក្នុងវិស័យអចលទ្រព្យចិន នឹងអាចជួបបញ្ហាសាច់ប្រាក់ នៅពេលដែលការលក់ធ្លាក់ចុះ ៣០%



*ប្រភព៖ CNBC ២០២១*

យោងតាមក្រុមហ៊ុន Fitch Ratings បានបង្ហាញថា ប្រមាណជា ១/៣ នៃក្រុមហ៊ុនសាងសង់អចលនទ្រព្យសរុបចំនួន ៤០ នឹងអាចប្រឈមបញ្ហាសាច់ប្រាក់ក្នុងប្រតិបត្តិការ ក្នុងករណីសេណារីយ៉ូអាក្រក់បំផុត ដែលចំណូលពីការលក់ផ្ទះនៅឆ្នាំក្រោយ នឹងធ្លាក់ចុះ ៣០%។ ភាពតានតឹងក្នុងវិស័យអចលនទ្រព្យចិនមានរយៈពេលកាន់តែវែង នោះការបាត់បង់ទំនុកចិត្តរបស់អ្នកប្រើប្រាស់ប្រឈមនឹងកើនឡើងកាន់តែខ្លាំង។

គួរបញ្ជាក់ថា ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ វិស័យអចលនទ្រព្យចិន បានជួបប្រទះនឹងវិបត្តិបំណុល នៅពេលដែល ក្រុមហ៊ុនសាងសង់ចិន Evergrande ដែលជាក្រុមហ៊ុនដែលជំពាក់បំណុលច្រើនបំផុតលើពិភព-លោក មិនមានលទ្ធភាពសងបំណុល។ ស្របពេលគ្នានេះដែរ ក្រុមហ៊ុនសាងសង់មួយចំនួន បានខកខានក្នុងការទូទាត់ការប្រាក់ ខណៈក្រុមហ៊ុនសាងសង់មួយចំនួនទៀត គ្មានលទ្ធភាពសងបំណុល។

គួរបញ្ជាក់ថា ទំនុកចិត្តអ្នកទិញគេហដ្ឋាន បានធ្លាក់ចុះក៏ដូចជា ការលក់លំនៅដ្ឋាន។ ជាក់ស្តែង នៅក្នុងវិច្ឆិកានេះ ការលក់គេហដ្ឋាន បានធ្លាក់ចុះ ១៦,៣១% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន និងជាខែទី ៥ ដែល

ការលក់បានបន្តធ្លាក់ចុះ។ បច្ចុប្បន្ន តម្លៃគេហដ្ឋានថ្មីបានធ្លាក់ចុះ ០,៣% បើធៀបនឹងខែមុន។

ដោយឡែក ចំពោះសេណារីយ៉ូមូលដ្ឋាន ដែលចំណូលពីការលក់គេហដ្ឋានធ្លាក់ចុះត្រឹម ១៥%នោះ ប្រមាណជា ១៣% នៃក្រុមហ៊ុនសាងសង់សរុប នឹងមានលំហូរសាច់ប្រាក់អវិជ្ជមាន៕ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ CNBC ចេញផ្សាយ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១*

## តម្លៃភាគហ៊ុនអាស៊ី និងប្រេងឆៅរង្គោះរង្គើ ដោយសារតែក្តីបារម្ភកើនឡើងទាក់ទងនឹងអូមីក្រុង




*ដោយ ខេមបូណ្ឌមីស*

តម្លៃភាគហ៊ុននៅអាស៊ី និងប្រេងឆៅរង្គោះរង្គើ ដោយសារតែក្តីបារម្ភកើនឡើងទៅនឹងអូមីក្រុង ដែលវាបានដាក់បន្ទុកទៅលើសតិអារម្មណ៍ និងការសម្រេចចិត្តរបស់អ្នកវិនិយោគភាគហ៊ុននៅអាស៊ី តួយ៉ាង ផ្សារភាគហ៊ុនធំៗនៅ ជប៉ុន កូរ៉េខាងត្បូង សៀងហៃ មានធ្លាក់ចុះទាំងអស់។ នៅថ្ងៃចន្ទដើមសប្តាហ៍នៃការបើកផាកការជួញដូរ គេសង្កេតឃើញថា តម្លៃភាគហ៊ុននៅអាស៊ីបានចុះទន់ខ្សោយមែនទែន ជាមួយនឹងការជួញដូរប្រេងឆៅក៏មានកម្រិតថយចុះដែរ។

អ្នកជំនាញខាងទីផ្សារមូលបត្រនៅជប៉ុននិយាយថា ការព្រួយបារម្ភពីការរីករាលដាលកាន់តែខ្លាំងក្លានៃមេរោគបំប្លែងថ្មីអូមីក្រុង បានធ្វើឱ្យអ្នកវិនិយោគមានការប្រយ័ត្នប្រយែងខ្ពស់ចំពោះការជួញដូរផ្សារភាគហ៊ុនពិសេសការទិញភាគហ៊ុនរបស់ក្រុមហ៊ុនដែមានតម្លៃថ្លៃៗ។

នៅរយៈពេលបីថ្ងៃចុងក្រោយនេះ ក្រុមហ៊ុនអាកាសចរណ៍របស់អាមេរិក បានលុបចោល និងពន្យារជើងហោះហើររាប់ពាន់ជើង ព្រោះកង្វះបុគ្គលិកអាកាសចរណ៍បម្រើការ ដោយសារតែមានជាប់ពាក់ព័ន្ធនឹងការឆ្លងកូវីដ១៩។ រីឯនាវាធ្វើដំណើរទេសចរណ៍ជាច្រើនទៀត ក៏បានលុបចោលការចូលចត ព្រោះរកឃើញករណីឆ្លងកូវីដ១៩នៅក្នុងកប៉ាល់។ នៅប្រទេសចិន ក៏បានរកឃើញករណីឆ្លងកូវីដ១៩ប្រចាំថ្ងៃកាន់តែខ្ពស់ទៅៗផងដែរ។

តម្លៃទីផ្សារប្រេងឆៅនៅទីផ្សារអាមេរិកឯណោះវិញ ក៏មានការធ្លាក់ចុះ៥៩សេនដែរ។ ក៏ប៉ុន្តែ សម្រាប់ប្រេងឆៅអង់គ្លេសវិញបែរជាមានការកើនឡើង២៦សេន ក្នុងមួយបារ៉ែល។ ទាក់ទងនឹងទីផ្សារប្រេងឆៅនេះដែរ អង្គការប្រទេសនាំចេញប្រេង និងសម្ព័ន្ធមិត្តរបស់ខ្លួនរួមមានប្រទេសរុស្ស៊ីផងដែរ នឹងធ្វើការសម្រេចចិត្តឆាប់ៗនេះ ថាតើពួកគេនឹងត្រូវបង្កើនការផលិតប្រេងឱ្យដល់៤០ម៉ឺនបារ៉ែលក្នុងមួយថ្ងៃ ឬក៏អត់ នៅក្នុងខែកុម្ភៈខាងមុខនេះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១។*

## គោលនយោបាយយុទ្ធសាស្រ្តថ្មីរបស់ចិន ដើម្បីរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចឆ្នាំ២០២២



*ដោយ ខេមបូណ្ឌមីស(រូបតំណាង៖ គោលនយោបាយយុទ្ធសាស្រ្តថ្មីរបស់ចិន)*

រដ្ឋាភិបាលចិន នឹងចាប់ផ្តើមកាត់បន្ថយពន្ធ និងការយកថ្លៃសេវាមួយចំនួនទៀត ដើម្បីគាំទ្រដល់អាជីវកម្មឱ្យមានសន្ទុះលឿនជាងមុន។ ជាក់ស្តែង ប្រទេសចិនបានបញ្ចេញទឹកប្រាក់មុនពេលកំណត់ ប្រមាណ ២២៩ ពាន់លានដុល្លារអាមេរិក នៅក្នុងកូតាឆ្នាំ ២០២២ សម្រាប់រដ្ឋបាលតាមតំបន់នៅទូទាំងប្រទេសចិនតែម្តងដើម្បីជួយជំរុញការវិនិយោគ គាំទ្រដល់អាជីវកម្ម និងគាំទ្រដល់សេដ្ឋកិច្ចរបស់ខ្លួនដែលបានដើរយឺតខុសពីការរំពឹងទុក។

ប្រាក់ចំណាយសារពើពន្ធ នឹងត្រូវចំណាយសម្រាប់ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ហើយរដ្ឋាភិបាលក្រុងប៉េកាំង នឹងបង្កើនការផ្ទេរថវិកាទៅកាន់រដ្ឋបាលតាមតំបន់ដើម្បីឱ្យប្រើប្រាស់លើចំណាយដែលចាំបាច់ដើម្បីជំរុញសេដ្ឋកិច្ច។ ចិនក៏នឹងចាត់វិធានការទប់ស្កាត់ការកើនឡើងនៃបំណុល របស់រដ្ឋបាលតាមតំបន់នៅឆ្នាំ ២០២២ ក៏ដូចជា ដើម្បីរក្សាស្ថិរភាពសង្គមទាំងមូលផងដែរ។

បច្ចុប្បន្ននេះចិនកំពុងប្រឈមមុខនឹងបញ្ហាជាច្រើន ដោយសារការធ្លាក់ចុះនៃវិស័យអចលនទ្រព្យ ការរាំងស្ទះការផ្គត់ផ្គង់ខ្សែចង្វាក់ផលិតកម្មដោយសារវិបត្តិថាមពល ការទប់ស្កាត់ដ៏តឹងរ៉ឹងនៃជំងឺកូវីដ-១៩ ដែលកំពុងរីករាលដាលឡើងវិញ និងផលប៉ះពាល់ដល់ការចំណាយរបស់អ្នកប្រើប្រាស់ជាដើម បានធ្វើឱ្យចិនប្រឈមមុខនឹងកំណើនសេដ្ឋកិច្ចយឺតជាងការរំពឹងទុក ដែលរដ្ឋអំណាចក្រុងប៉េកាំង ត្រូវរៀបចំផែនការថ្មីដែលគ្រោងនឹងដាក់ចេញនូវគោលនយោបាយសារពើពន្ធថ្មីដែលដើរតួនាទីសកម្មជាងមុន ប្រសិទ្ធិភាពជាងមុនដើម្បីរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចនៅឆ្នាំ២០២២ ក្រោយពីបានកត់សម្គាល់ពីការធ្លាក់ចុះកំណើនសេដ្ឋកិច្ចរបស់ខ្លួននៅក្នុងឆមាសទី២ ឆ្នាំ២០២១ ខុសពីការរំពឹងទុក។

ទន្ទឹមនឹងការដាក់ចេញគោលនយោបាយដើម្បីរក្សាស្ថិរភាពសេដ្ឋកិច្ច ប្រទេសចិនកំពុងពិចារណាបន្ទាបគោលដៅកំណើនសេដ្ឋកិច្ចឆ្នាំ ២០២២ របស់ចិនមកត្រឹម ៥,៥%វិញ ខុសពីគោលដៅដែលបានដាក់ចេញកាលពីឆ្នាំ ២០២១ ដែលថា សេដ្ឋកិច្ចចិននឹងសម្រេចបានឱ្យរង្វង់៦% ឬច្រើនជាងនេះ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី០៣ ខែមករា ឆ្នាំ២០២២

- អត្រាអតិផរណាប្រចាំឆ្នាំរបស់ប្រទេសឥណ្ឌូនេស៊ីបានកើនឡើងដល់កម្រិតខ្ពស់
- ឱនភាពពាណិជ្ជកម្មរបស់ឥណ្ឌា ត្រូវបានកែសម្រួលទាប មកត្រឹម 22.9 ពាន់លានដុល្លារ ក្នុងខែវិច្ឆិកា

ថ្ងៃអង្គារ ទី០៤ ខែមករា ឆ្នាំ២០២២

- ប្រទេសប្រេស៊ីលបានកត់ត្រាឱនភាពពាណិជ្ជកម្មក្នុងខែវិច្ឆិកា ឆ្នាំ 2021
- ចំណូលពន្ធនៅក្នុងប្រទេសអាហ្សង់ទីនបានកើនឡើង ក្នុងខែវិច្ឆិកា ឆ្នាំ 2021

ថ្ងៃពុធ ទី០៥ ខែមករា ឆ្នាំ២០២២

- ចំនួនមនុស្សដែលបានចុះឈ្មោះជាអ្នកអត់ការងារធ្វើនៅក្នុងប្រទេសអេស្ប៉ាញបានធ្លាក់ចុះ ក្នុងខែវិច្ឆិកា ឆ្នាំ 2021
- សូចនាករទំនុកចិត្តអ្នកប្រើប្រាស់របស់ប្រទេសអេស្ប៉ាញបានធ្លាក់ចុះ ក្នុងខែវិច្ឆិកា ឆ្នាំ 2021

ថ្ងៃព្រហស្បតិ៍ ទី០៦ ខែមករា ឆ្នាំ២០២២

- អត្រាអតិផរណាប្រចាំឆ្នាំនៅប្រទេសអាឡឺម៉ង់ បានកើនឡើងដល់ 5.2% ក្នុងខែវិច្ឆិកា ឆ្នាំ 2021
- ឱនភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកបាន រួមតូចយ៉ាងខ្លាំង ក្នុងខែតុលា ឆ្នាំ 2021

ថ្ងៃសុក្រ ទី០៧ ខែមករា ឆ្នាំ២០២២

- អតិរេកពាណិជ្ជកម្មនៅប្រទេសអាឡឺម៉ង់បាន ធ្លាក់ចុះយ៉ាងខ្លាំង ក្នុងខែតុលា ឆ្នាំ 2021
- សូចនាករមនោសញ្ចេតនាសេដ្ឋកិច្ច( The economic sentiment )នៅក្នុងតំបន់អឺរ៉ូ បានធ្លាក់ចុះ ក្នុងខែវិច្ឆិកា 2021៕